**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៤៣១៤ កសក

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែ[illegible] ឆ្នាំ ២០១៥

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ÷** របាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំពិភាក្សា និងវាយតម្លៃអំពីស្ថានភាពការងារបង្កបង្កើនផលរដូវវស្សាឆ្នាំ២០១៥ និងវិធានការជំរុញការងារបង្កបង្កើនផលរដូវប្រាំងឆ្នាំ២០១៥-២០១៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតគោរពជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់ មេត្តាជ្រាបថា នៅថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ២០១៥ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំកិច្ចប្រជុំមួយ ដែលមានការចូលរួមពីថ្នាក់ដឹកនាំក្រសួង គ្រប់អង្គភាពក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី ខេត្ត ដើម្បីវាយតម្លៃ និងបូកសរុបលទ្ធផលបឋមនៃការងារបង្កបង្កើនផលរដូវវស្សាឆ្នាំ២០១៥ និងវិធានការជំរុញការងារបង្កបង្កើនផលរដូវប្រាំងឆ្នាំ២០១៥-២០១៦ ដោយទទួលបានលទ្ធផលដូចខាងក្រោម ÷

## I- ស្ថានភាពទូទៅក្នុងឆ្នាំ២០១៥

នៅក្នុងឆ្នាំនេះ ស្ថានភាពនៃការងារបង្កបង្កើនផលមានការប្រែប្រួល អាស្រ័យដោយសារអាកាសធាតុមិនអំណោយផល ទឹកភ្លៀងធ្លាក់យឺតជាងឆ្នាំកន្លងមក និងគ្រោះរាំងស្ងួតបានអូសបន្លាយពេលយូរ នៅដើមរដូវវស្សា ។ ជាមួយគ្នានេះដែរ ទឹកទន្លេឆ្នាំនេះមានកម្រិតទាបមិនអាចហូរចូលព្រែកបាន ក៏ជាកត្តាមួយជះឥទ្ធិពលដល់ការងារបង្កបង្កើនផលទាំងរដូវវស្សា និងរដូវប្រាំងផងដែរ ។ តែទោះជាយ៉ាងណាការងារបង្កបង្កើនផលរដូវវស្សា ក៏ដូចជារដូវប្រាំង មិនមានទទួលរងនូវជំងឺ ឬ សត្វចង្រៃបំផ្លាញផលដំណាំឡើយ។ ម្យ៉ាងទៀត តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រីជំនាញនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការងារផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក៏ដូចជាការថែទាំដំណាំតាមដំណាក់កាលលូតលាស់ ការប្រើប្រាស់ពូជល្អ ពេញនិយមនិងមានទិន្នផលខ្ពស់ ស្របតាមតម្រូវការនៃទីផ្សារ គួបផ្សំនឹងការកាត់បន្ថយការប្រើប្រាស់ជីកសិកម្ម និងកត្តាផលិតកម្មផ្សេងៗទៀត បានធ្វើឱ្យការងារបង្កបង្កើនផលទទួលលទ្ធផលជាវិជ្ជមាន ។

## II- លទ្ធផលនៃការងារបង្កបង្កើនផលឆ្នាំ២០១៥-២០១៦

១. ដំណាំស្រូវរដូវវស្សាឆ្នាំ២០១៥ (ដូចមានតារាងគោរពជូនភ្ជាប់)

ក. ភ្ជួររាស់រៀបចំដីសម្រេចបានចំនួន៣.៥៥៣.៨៨៧ហត ក្នុងនោះ ភ្ជួររាស់ដោយគោ ក្របីចំនួន ៤៣៤.៣៩៧ហត និងដោយគ្រឿងយន្តចំនួន៣.១១៩.៤៩០ហត លើសឆ្នាំមុន៥៧៣.៧៧០ហត។

**ខ. សាប**សម្រេចបានចំនួន**៧១.០៧៣ហត** តិចជាងឆ្នាំមុន៤២.២៨៩ហត។

**គ. ស្ទូងនិងព្រោះ**សម្រេចបានចំនួន**២.៥៦១.៩៥៧ហត** ស្មើនឹង៩៩,៨០% នៃផែនការ ២.៥៦៧.១៣០ ហត តែតិចជាងឆ្នាំមុន ២.៦១៥ ហត។ ស្រូវតាមប្រភេទសម្រេចបានរួមមាន÷

- ស្រូវស្រាលចំនួន **៥៨៣.៧០៦ ហត** (ក្នុងនោះស្រូវបង្កើនរដូវចំនួន**១៣៣.៧២៦ហត**) តិចជាងឆ្នាំមុន ៧៧.៤០០ ហត
- ស្រូវកណ្តាលចំនួន **១.៣១៤.៧៦៧ ហត** លើសឆ្នាំមុន ៥៨.៥០៨ ហត
- ស្រូវធ្ងន់ចំនួន **៥៧៩.៩៤២ ហត** លើសឆ្នាំមុន ២៩.៣៦២ ហត
- ស្រូវចម្ការចំនួន **៣៦.៧៨៣ ហត** តិចជាងឆ្នាំមុន ៧.៣០៥ ហត
- ស្រូវឡើងទឹកចំនួន **៤៦.៧៥៩ ហត** តិចជាងឆ្នាំមុន ៥.៧៨០ ហត។

**ឃ. ផ្ទៃដីប៉ះពាល់និងខូចខាតដោយគ្រោះធម្មជាតិ**

- សន្ទូង ពង្រោះប៉ះពាល់សរុបចំនួន**២៤២.៤១៦ហត** (ស្មើនឹង៩% នៃផ្ទៃដីអនុវត្ត**២.៥៦១.៩៥៧ ហត**) ក្នុងនោះ ខូចខាតទាំងស្រុងអស់ចំនួន **២៥.៧៦០ ហត**។

**ង. ផ្ទៃដីប្រមូលផល**

ផ្ទៃដីប្រមូលផលសរុបនឹងអាចទទួលបានចំនួនប្រមាណ **២.៥៣៦.១៩៧ ហត** តែតិចជាងឆ្នាំ ២០១៤ ចំនួន **១.៧៧៩ ហត** ។ ទិន្នផលជាមធ្យមប៉ាន់ស្មានអាចនឹងទទួលបាន **២,៨២៩ តោន/ហត** លើសឆ្នាំមុនចំនួន **១៤គក្រ/ហត** និងបរិមាណផលសរុបប្រមាណ **៧.១៧៤.៥៤៩តោន** កើនលើសឆ្នាំមុនចំនួន **៣១.០២៨ តោន** ។

**២. លទ្ធផលប៉ាន់ស្មានដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៥-២០១៦** (ដូចមានតារាងគោរពជូនភ្ជាប់)

ការងារបង្កបង្កើនផលស្រូវរដូវប្រាំង ឆ្នាំ២០១៥-២០១៦ គិតរហូតមកដល់ថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ ២០១៥ អនុវត្តបានចំនួន **២០៤.២៧៩ ហត** ស្មើនឹង **៤៨,៩៥%** នៃផែនការ ៤១៧.៣២៥ ហត តែតិចជាងរយៈពេលដូចគ្នានៃឆ្នាំមុន **១៥.១៣៥ ហត** ។ ដោយផ្អែកលើនិន្នាការនេះ ក្រសួងបានប៉ាន់ស្មានថា ផ្ទៃដីសរុបអាចសម្រេចបានមានចំនួន**៤៦៥.១៦៧ ហត** ដែលក្នុងនោះអាចប្រមូលផលបានមានចំនួន ៤៦០.០៦២ហត ហើយបរិមាណផលស្រូវសរុប ស្ថិតក្នុងរង្វង់ **២.០៥២.៤៧២ តោន** គឺតិចជាងឆ្នាំមុនចំនួន **១២៨.៤២៤ តោន** ក្នុងកម្រិតទិន្នផលជាមធ្យម **៤,៤៦១ តោន/ហត** (ទិន្នផលឆ្នាំមុន៤,៤៤៣ តោន/ហត)។

**III- សេចក្តីសន្និដ្ឋាន**

ការងារបង្កបង្កើនផលឆ្នាំនេះ បានជួបប្រទះឥទ្ធិពលអវិជ្ជមានបណ្តាលមកពីគ្រោះរាំងស្ងួត ទឹកទន្លេមានកម្រិតទាប ធ្វើឱ្យផ្ទៃដីដាំដុះថយចុះ ធៀបនឹងឆ្នាំមុន តែទិន្នផលជាមធ្យមមានការកើនឡើង ហើយបរិមាណផលមិនមានការថយចុះខ្លាំងជាងឆ្នាំមុននោះឡើយ ។ ម្យ៉ាងទៀត វឌ្ឍនភាពនៃការធ្វើប្រពលវប្បកម្មដំណាំស្រូវ ពុំទាន់អនុវត្តឱ្យបានពេញលេញតាមបច្ចេកទេសកសិកម្មសមស្រប ជាកត្តាធ្វើឱ្យទិន្នផលមធ្យមនៅមានកម្រិតទាប គួបផ្សំនឹងការចំណាយថ្លៃដើមផលិតកម្មមានកម្រិតខ្ពស់ ។ បច្ចុប្បន្ននេះ ការប្រើប្រាស់សេវាភ្ជួររាស់ដោយគ្រឿងយន្តកសិកម្ម ក្នុងការរៀបចំដីដាំដុះ មានការកើនឡើងដល់ជាង ៨០% ធៀបនឹងផ្ទៃដីភ្ជួររាស់សរុប (**៣.៥៥៣.៨៨៧ហត**) ដែលមធ្យោបាយនេះបានបង្ហាញពីការអនុវត្ត

កាន់តែបានល្អប្រសើរតាមបច្ចេកទេសមស្រប។ ប៉ុន្តែនៅមានកត្តាផ្សេងៗទៀតក្នុងប្រព័ន្ធប្រពលវប្បកម្ម ដូចជាកត្តាបច្ចេកទេស និងដើមទុនផលិតកម្មរបស់កសិករ ដែលត្រូវបានផ្តល់អាទិភាពសម្រាប់ជំរុញផលិតកម្មដំណាំស្រូវ ក៏ដូចជាដំណាំផ្សេងៗទៀតផងដែរ។

តាមរយៈការបូកសរុបបឋម លទ្ធផលប៉ាន់ស្មានជំហានដំបូងលើការងារបង្កបង្កើនផលស្រូវឆ្នាំ២០១៥-២០១៦ នឹងអាចសម្រេចបានលើផ្ទៃដីបង្កបង្កើនផលចំនួន៣.០២៧.១២៤ហត (រដូវវស្សា ២.៥៦១.៩៥៧ហត + រដូវប្រាំង៤៦៥.១៦៧ហត= ៣.០២៧.១២៤ហត) គឺតិចជាងឆ្នាំមុនចំនួន ២៨.៣៨៣ហត (ឆ្នាំមុនអនុវត្តបានចំនួន៣.០៥៥.៥០៧ហត)។ ផ្ទៃដីប្រមូលផលសរុបអាចទទួលបានចំនួន **២.៩៩៦.២៥៩**ហត (រដូវវស្សា២.៥៣៦.១៩៧ហត + រដូវប្រាំង៤៦០.០៦២ហត= ២.៩៩៦.២៥៩ ហត) គឺតិចជាងឆ្នាំមុនចំនួន៣២.៥៧៧ហត (ឆ្នាំមុន៣,០២៨លានហត) ។ បរិមាណផលប៉ាន់ស្មានសរុប **៩.២២៧.០២១**តោន (ឆ្នាំមុន៩,៣២លានតោន) និងទិន្នផលមធ្យមទូទាំងប្រទេស៣,០៨០តោន/ហត (ឆ្នាំមុន៣,០៧៩តោន/ហត) ។ ដូច្នេះ បើគិតពីតុល្យភាពស្បៀងរវាងសេចក្តីត្រូវការ និងបរិមាណផលស្រូវទទួលបានឃើញថា អាចនៅសល់បរិមាណស្បៀងគិតជាស្រូវជាង៤,៥លានតោន (ឆ្នាំមុនសម្រេចបាន៤,៧លានតោន) និងគិតជាអង្ករប្រមាណជាង ២,៩១លានតោន (ឆ្នាំមុនជាង៣,០១លានតោន) សម្រាប់នាំចេញ។

អាស្រ័យហេតុដូចបានគោរពរាយការណ៍ជូនខាងលើនេះ ខ្ញុំបាទសូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់ មេត្តាជ្រាបដោយក្តីអនុគ្រោះ។

សូម **សម្តេចតេជោ នាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅបំផុតពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  "ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានផែនការនិងស្ថិតិ

# លទ្ធផលបញ្ចប់ការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៥

((យោងកិច្ចប្រជុំថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥)

| ល.រ | រាជធានី-ខេត្ត | ផែនការ | ផ្ទៃដីភ្ជួររាស់ (ហ.ត) | | | | | ផ្ទៃដីសាប | ផ្ទៃដីព្រោះស្ទូង និងបុកដាំ (ហ.ត) | | | | | | សរុបស្ទូង និងព្រោះបុកដាំ (ហ.ត) | ភាគរយ (%) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប | គោ-ក្របី | | គ្រឿងយន្ត | | | ស្រូវស្រាល | | កណ្តាល | ធ្ងន់ | ចម្ការ | ឡើងទឹក | | |
| | | | | ហ.ត | % | ហ.ត | % | | សរុប | បង្កើនរដូវ | | | | | | |
| 01 | បន្ទាយមានជ័យ | 244,000 | 246,567 | 45 | 0.02 | 246,522 | 99.98 | 48 | 54,693 | 36,388 | 132,708 | 48,505 | - | 10,115 | 246,021 | 100.83 |
| 02 | បាត់ដំបង | 295,400 | 290,786 | 1,783 | 0.61 | 289,003 | 99.39 | 416 | 60,937 | 30,322 | 127,998 | 92,732 | 435 | 7,954 | 290,056 | 98.19 |
| 03 | កំពង់ចាម | 87,300 | 667,033 | 16,488 | 2.47 | 650,545 | 97.53 | 1,439 | 22,745 | 5,129 | 33,699 | 29,652 | - | 1,050 | 87,146 | 99.82 |
| 04 | កំពង់ឆ្នាំង | 121,800 | 173,882 | 48,919 | 28.13 | 124,963 | 71.87 | 12,777 | 5,048 | 938 | 90,486 | 26,707 | - | 340 | 122,581 | 100.64 |
| 05 | កំពង់ស្ពឺ | 107,900 | 209,781 | 95,761 | 45.65 | 114,020 | 54.35 | 10,059 | 15,190 | 718 | 67,537 | 28,746 | 1,174 | - | 112,647 | 104.40 |
| 06 | កំពង់ធំ | 213,300 | 215,878 | 53,086 | 24.59 | 162,792 | 75.41 | 3,611 | 28,288 | 6,997 | 106,787 | 62,961 | 3,225 | 12,165 | 213,426 | 100.06 |
| 07 | កំពត | 136,500 | 136,537 | 38,624 | 28.29 | 97,913 | 71.71 | 12,029 | 20,891 | - | 69,949 | 45,697 | - | - | 136,537 | 100.03 |
| 08 | កណ្តាល | 40,100 | 46,459 | 9,660 | 20.79 | 36,799 | 79.21 | 1,392 | 9,749 | 6,189 | 12,659 | 11,704 | 1,121 | 47 | 35,280 | 87.98 |
| 09 | កោះកុង | 10,400 | 9,183 | 2,280 | 24.83 | 6,903 | 75.17 | 778 | 2,032 | - | 6,161 | 992 | 1,220 | - | 10,405 | 100.05 |
| 10 | ក្រចេះ | 33,000 | 33,235 | 10,025 | 30.16 | 23,210 | 69.84 | 3,345 | 13,142 | 821 | 15,301 | 3,595 | 248 | - | 32,286 | 97.84 |
| 11 | មណ្ឌលគិរី | 23,000 | 23,875 | 273 | 1.14 | 23,602 | 98.86 | 2,835 | 2,750 | - | 11,383 | 5,169 | 3,627 | - | 22,929 | 99.69 |
| 12 | ភ្នំពេញ | 11,300 | 11,156 | 3,686 | 33.04 | 7,470 | 66.96 | 836 | 5,536 | - | 3,612 | 2,005 | - | - | 11,153 | 98.70 |
| 13 | ព្រះវិហារ | 76,600 | 76,924 | 4,066 | 5.29 | 72,858 | 94.71 | 2,888 | 12,799 | - | 43,826 | 23,819 | 2,944 | - | 83,388 | 108.86 |
| 14 | ព្រៃវែង | 272,800 | 269,415 | 13,061 | 4.85 | 256,354 | 95.15 | 24 | 66,631 | - | 143,389 | 58,141 | - | 154 | 268,315 | 98.36 |
| 15 | ពោធិ៍សាត់ | 111,200 | 111,014 | 6,693 | 6.03 | 104,321 | 93.97 | 3,432 | 44,491 | 380 | 36,009 | 19,759 | 396 | 7,674 | 108,329 | 97.42 |
| 16 | រតនគិរី | 26,100 | 14,486 | 4,966 | 34.28 | 9,520 | 65.72 | 1,241 | 3,901 | - | 5,414 | 5,172 | 11,531 | - | 26,018 | 99.69 |
| 17 | សៀមរាប | 184,200 | 222,180 | 48,370 | 21.77 | 173,810 | 78.23 | 5,804 | 38,425 | - | 93,530 | 41,405 | 5,430 | 7,260 | 186,050 | 101.00 |
| 18 | ព្រះសីហនុ | 16,600 | 16,614 | 4,154 | 25.00 | 12,460 | 75.00 | 373 | 1,484 | - | 10,415 | 4,715 | - | - | 16,614 | 100.08 |
| 19 | ស្ទឹងត្រែង | 27,900 | 25,905 | 6,943 | 26.80 | 18,962 | 73.20 | 2,365 | 13,014 | - | 11,749 | 1,142 | 2,784 | - | 28,689 | 102.83 |
| 20 | ស្វាយរៀង | 167,000 | 168,641 | 9,941 | 5.89 | 158,700 | 94.11 | 280 | 51,409 | 9,936 | 108,014 | 8,523 | - | - | 167,946 | 100.57 |
| 21 | តាកែវ | 199,800 | 415,882 | 50,053 | 12.04 | 365,829 | 87.96 | 1,379 | 79,766 | 33,703 | 107,416 | 10,052 | - | - | 197,234 | 98.72 |
| 22 | ឧត្តរមានជ័យ | 72,100 | 81,545 | 565 | 0.69 | 80,980 | 99.31 | 1,080 | 16,664 | - | 40,571 | 12,117 | 2,648 | - | 72,000 | 99.86 |
| 23 | កែប | 3,500 | 3,588 | 1,488 | 41.47 | 2,100 | 58.53 | 600 | 836 | 239 | 2,235 | 517 | - | - | 3,588 | 102.51 |
| 24 | ប៉ៃលិន | 6,230 | 5,003 | | - | 5,003 | 100.00 | 2 | 1,837 | - | 3,107 | 57 | - | - | 5,001 | 80.27 |
| 25 | ត្បូងឃ្មុំ | 79,100 | 78,318 | 3,467 | 4.43 | 74,851 | 95.57 | 2,040 | 11,448 | 1,966 | 30,812 | 36,058 | - | - | 78,318 | 99.01 |
| **សរុប** | | **2,567,130** | **3,553,887** | **434,397** | **12.22** | **3,119,490** | **87.78** | **71,073** | **583,706** | **133,726** | **1,314,767** | **579,942** | **36,783** | **46,759** | **2,561,957** | **99.80** |
| **តួលេខឆ្នាំមុន** | | **2,411,207** | **2,980,117** | **715,184** | **24.00** | **2,264,933** | **76.00** | **113,362** | **661,106** | **176,242** | **1,256,259** | **550,580** | **44,088** | **52,539** | **2,564,572** | **106.36** |
| **ប្រៀបធៀបឆ្នាំមុន** | | **155,923** | **573,770** | **-280,787** | **-11.78** | **854,557** | **11.78** | **-42,289** | **-77,400** | **-42,516** | **58,508** | **29,362** | **-7,305** | **-5,780** | **-2,615** | **-6.56** |

**បានឃើញនិងឯកភាព**

ក. ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០១៥

ប្រធានការិយាល័យស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានផែនការនិងស្ថិតិ

# លទ្ធផលប៉ាន់ស្មានបណ្តោះអាសន្នស្រូវរដូវវស្សាឆ្នាំ២០១៥ និងរដូវប្រាំងឆ្នាំ២០១៥-២០១៦

| ល.រ | រាជធានី-ខេត្ត | រដូវវស្សាឆ្នាំ២០១៥ | | | | ប៉ាន់ស្មានរដូវប្រាំងឆ្នាំ២០១៥-២០១៦ | | | | សរុបប្រចាំឆ្នាំ២០១៥-២០១៦ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផ្ទៃដីដាំដុះ (ហត) | ផ្ទៃដីប្រមូលផល (ហត) | ទិន្នផល (ត/ហត) | បរិមាណផល (តោន) | ផ្ទៃដីដាំដុះ (ហត) | ផ្ទៃដីប្រមូលផល (ហត) | ទិន្នផល (ត/ហត) | បរិមាណផល (តោន) | ផ្ទៃដីដាំដុះ (ហត) | ផ្ទៃដីប្រមូលផល (ហត) | ទិន្នផល (ត/ហត) | បរិមាណផល (តោន) |
| 01 | បន្ទាយមានជ័យ | 246,021 | 235,222 | 2.664 | 626,646 | 20,000 | 20,000 | 4.090 | 81,800 | 266,021 | 255,222 | 2.776 | 708,446 |
| 02 | បាត់ដំបង | 290,056 | 279,123 | 2.860 | 798,292 | 10,500 | 10,500 | 3.980 | 41,790 | 300,556 | 289,623 | 2.901 | 840,082 |
| 03 | កំពង់ចាម | 87,146 | 87,146 | 3.220 | 280,610 | 29,835 | 29,835 | 4.160 | 124,114 | 116,981 | 116,981 | 3.460 | 404,724 |
| 04 | កំពង់ឆ្នាំង | 122,581 | 122,483 | 2.820 | 345,402 | 34,325 | 33,725 | 4.500 | 151,763 | 156,906 | 156,208 | 3.183 | 497,165 |
| 05 | កំពង់ស្ពឺ | 112,647 | 112,647 | 3.040 | 342,447 | 550 | 550 | 3.500 | 1,925 | 113,197 | 113,197 | 3.042 | 344,372 |
| 06 | កំពង់ធំ | 213,426 | 213,426 | 2.480 | 529,296 | 42,456 | 42,456 | 4.300 | 182,561 | 255,882 | 255,882 | 2.782 | 711,857 |
| 07 | កំពត | 136,537 | 136,537 | 3.150 | 430,092 | 8,660 | 8,660 | 4.100 | 35,506 | 145,197 | 145,197 | 3.207 | 465,598 |
| 08 | កណ្តាល | 35,280 | 35,280 | 3.032 | 106,967 | 53,500 | 53,500 | 4.210 | 225,235 | 88,780 | 88,780 | 3.742 | 332,202 |
| 09 | កោះកុង | 10,405 | 10,405 | 2.850 | 29,654 | - | - | - | - | 10,405 | 10,405 | 2.850 | 29,654 |
| 10 | ក្រចេះ | 32,286 | 32,286 | 2.672 | 86,263 | 13,453 | 13,453 | 4.263 | 57,350 | 45,739 | 45,739 | 3.140 | 143,613 |
| 11 | មណ្ឌលគិរី | 22,929 | 22,929 | 2.368 | 54,296 | - | - | - | - | 22,929 | 22,929 | 2.368 | 54,296 |
| 12 | ភ្នំពេញ | 11,153 | 11,153 | 2.898 | 32,316 | 1,361 | 1,361 | 3.503 | 4,768 | 12,514 | 12,514 | 2.963 | 37,084 |
| 13 | ព្រះវិហារ | 83,388 | 83,388 | 2.738 | 228,303 | 100 | 100 | 3.000 | 300 | 83,488 | 83,488 | 2.738 | 228,603 |
| 14 | ព្រៃវែង | 268,315 | 268,315 | 2.996 | 803,872 | 92,000 | 92,000 | 4.824 | 443,808 | 360,315 | 360,315 | 3.463 | 1,247,680 |
| 15 | ពោធិ៍សាត់ | 108,329 | 105,593 | 3.034 | 320,365 | 11,686 | 11,686 | 4.178 | 48,819 | 120,015 | 117,279 | 3.148 | 369,184 |
| 16 | រតនៈគិរី | 26,018 | 26,018 | 2.031 | 52,853 | - | - | - | - | 26,018 | 26,018 | 2.031 | 52,853 |
| 17 | សៀមរាប | 186,050 | 185,220 | 2.480 | 459,369 | 20,925 | 16,470 | 4.083 | 67,239 | 206,975 | 201,690 | 2.611 | 526,608 |
| 18 | ព្រះសីហនុ | 16,614 | 16,614 | 2.779 | 46,175 | - | - | - | - | 16,614 | 16,614 | 2.779 | 46,175 |
| 19 | ស្ទឹងត្រែង | 28,689 | 28,689 | 2.600 | 74,591 | 100 | 100 | 3.500 | 350 | 28,789 | 28,789 | 2.603 | 74,941 |
| 20 | ស្វាយរៀង | 167,946 | 167,658 | 2.610 | 437,587 | 19,000 | 18,950 | 4.270 | 80,917 | 186,946 | 186,608 | 2.779 | 518,504 |
| 21 | តាកែវ | 197,234 | 197,234 | 3.282 | 647,322 | 95,000 | 95,000 | 4.810 | 456,956 | 292,234 | 292,234 | 3.779 | 1,104,278 |
| 22 | ឧត្តរមានជ័យ | 72,000 | 72,000 | 2.300 | 165,600 | 600 | 600 | 3.500 | 2,100 | 72,600 | 72,600 | 2.310 | 167,700 |
| 23 | កែប | 3,588 | 3,588 | 3.222 | 11,561 | 30 | 30 | 3.700 | 111 | 3,618 | 3,618 | 3.226 | 11,672 |
| 24 | ប៉ៃលិន | 5,001 | 4,925 | 2.633 | 12,968 | 786 | 786 | 3.601 | 2,830 | 5,787 | 5,711 | 2.766 | 15,798 |
| 25 | ត្បូងឃ្មុំ | 78,318 | 78,318 | 3.214 | 251,702 | 10,300 | 10,300 | 4.100 | 42,230 | 88,618 | 88,618 | 3.317 | 293,932 |
| សរុប | | **2,561,957** | **2,536,197** | **2.829** | **7,174,549** | **465,167** | **460,062** | **4.461** | **2,052,472** | **3,027,124** | **2,996,259** | **3.080** | **9,227,021** |
| តួលេខឆ្នាំមុន | | **2,564,572** | **2,537,976** | **2.815** | **7,143,521** | **490,935** | **490,860** | **4.443** | **2,180,896** | **3,055,507** | **3,028,836** | **3.079** | **9,324,416** |
| ប្រៀបធៀបឆ្នាំមុន | | **-2,615** | **-1,779** | **0.014** | **31,028** | **-25,768** | **-30,798** | **0.018** | **-128,424** | **-28,383** | **-32,577** | **0.001** | **-97,395** |

បានឃើញនិងឯកភាព
ត. ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០១៥
ប្រធានការិយាល័យស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផែនការ និង ស្ថិតិ

## ល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៥-២០១៦

(គិតត្រឹមថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៥)

| ល.រ | រាជធានី-ខេត្ត | ផែនការ (ហ.ត) | ផ្ទៃដីភ្ជួររាស់ សរុប (ហ.ត) | គោ-ក្របី ហ.ត | គោ-ក្របី % | គ្រឿងយន្ត ហ.ត | គ្រឿងយន្ត % | ផ្ទៃដីសាប (ហ.ត) | ផ្ទៃដីស្ទូង និងព្រោះ (ហត) សន្ទូង | ពង្រោះ | សរុប | ភាគរយ | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 01 | បន្ទាយមានជ័យ | 13,200 | 19,602 | | - | 19,602 | 100.00 | - | - | 19,328 | 19,328 | 146.42 | 30-11-2015 |
| 02 | បាត់ដំបង | 10,500 | 3,680 | | - | 3,680 | 100.00 | - | - | 3,680 | 3,680 | 35.05 | 17-11-2015 |
| 03 | កំពង់ចាម | 42,000 | 13,120 | 2,959 | 22.55 | 10,161 | 77.45 | 88 | 625 | 10,730 | 11,355 | 27.04 | 23-11-2015 |
| 04 | កំពង់ឆ្នាំង | 29,700 | 18,387 | 188 | 1.02 | 18,199 | 98.98 | 188 | - | 18,199 | 18,199 | 61.28 | 02-12-2015 |
| 05 | កំពង់ស្ពឺ | 550 | - | | - | | - | - | - | - | - | - | |
| 06 | កំពង់ធំ | 36,000 | 22,006 | - | - | 22,006 | 100.00 | 36 | 108 | 20,276 | 20,384 | 56.62 | 27-11-2015 |
| 07 | កំពត | 7,000 | 5,097 | | - | 5,097 | 100.00 | - | - | 5,097 | 5,097 | 72.81 | 30-11-2015 |
| 08 | កណ្តាល | 53,500 | 13,500 | 1,363 | 10.10 | 12,137 | 89.90 | - | - | 12,181 | 12,181 | 22.77 | 23-11-2015 |
| 09 | កោះកុង | - | - | | - | | - | - | - | - | - | - | |
| 10 | ក្រចេះ | 14,000 | 14,302 | 2,856 | 19.97 | 11,446 | 80.03 | 366 | 1,554 | 7,564 | 9,118 | 65.13 | 30-11-2015 |
| 11 | មណ្ឌលគិរី | - | - | | - | | - | - | - | - | - | - | |
| 12 | ភ្នំពេញ | 1,440 | - | | - | | - | - | - | - | - | - | |
| 13 | ព្រះវិហារ | 130 | - | | - | | - | - | - | - | - | - | |
| 14 | ព្រៃវែង | 75,000 | 50,629 | | - | 50,629 | 100.00 | - | - | 50,629 | 50,629 | 67.51 | 01-12-2015 |
| 15 | ពោធិ៍សាត់ | 8,300 | 9,133 | | - | 9,133 | 100.00 | - | - | 7,642 | 7,642 | 92.07 | 01-12-2015 |
| 16 | រតនះគិរី | - | - | | - | | - | - | - | - | - | - | |
| 17 | សៀមរាប | 20,925 | 17,395 | 150 | 0.86 | 17,245 | 99.14 | - | - | 9,110 | 9,110 | 43.54 | 17-11-2015 |
| 18 | ព្រះសីហនុ | - | - | | - | | - | - | - | - | - | - | |
| 19 | ស្ទឹងត្រែង | 100 | - | | - | | - | - | - | - | - | - | |
| 20 | ស្វាយរៀង | 17,850 | 10,100 | | - | 10,100 | 100.00 | - | - | 10,539 | 10,539 | 59.04 | 19-11-2015 |
| 21 | តាកែវ | 75,000 | 55,783 | 479 | 0.86 | 55,304 | 99.14 | - | - | 19,143 | 19,143 | 25.52 | 23-11-2015 |
| 22 | ឧត្តរមានជ័យ | 600 | - | | - | | - | - | - | - | - | - | |
| 23 | កែប | 30 | 32 | 11 | 34.38 | 21 | 65.63 | - | - | 25 | 25 | 83.33 | 01-12-2015 |
| 24 | ប៉ៃលិន | 1,000 | - | | - | | - | - | - | - | - | - | |
| 25 | ត្បូងឃ្មុំ | 10,500 | 7,955 | 254 | 3.19 | 7,701 | 96.81 | 67 | 579 | 7,270 | 7,849 | 74.75 | 04-12-2015 |
| **សរុប** | | **417,325** | **260,721** | **8,260** | **3.17** | **252,461** | **96.83** | **745** | **2,866** | **201,413** | **204,279** | **48.95** | |
| **តួលេខសប្តាហ៍មុន** | | **417,325** | **244,300** | **8,172** | **3.35** | **236,128** | **96.65** | **726** | **2,559** | **191,312** | **193,871** | **46.46** | |
| **តួលេខឆ្នាំមុន** | | **415,965** | **250,467** | **17,770** | **7.09** | **232,697** | **92.91** | **3,009** | **2,680** | **216,734** | **219,414** | **52.75** | |
| **ប្រៀបធៀបឆ្នាំមុន** | | **1,360** | **10,254** | **-9,510** | **-3.93** | **19,764** | **3.93** | **-2,264** | **186** | **-15,321** | **-15,135** | **-3.80** | |

បានឃើញនិងឯកភាព

ក. ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០១៥

ប្រធានការិយាល័យស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានផែនការ និង ស្ថិតិ

# ស្ថានភាពផ្ទៃដីប៉ះពាល់និងខូចខាតស្រូវវស្សាឆ្នាំ ២០១៥

(គិតត្រឹមថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៥)

| រាជធានី ខេត្ត | ផ្ទៃដី អនុវត្ត (ហ.ត) | ប៉ះពាល់ (ហ.ត) | | | | | | សរុប ប៉ះពាល់ (ហ.ត) | | ខូចខាត (ហ.ត) | | | | | | សរុប ខូចខាត (ហ.ត) | | ផ្ទៃដីស្តារឡើងវិញ (ហ.ត) | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | កង្វះខាតទឹក | | សត្វល្អិត | | ទឹកជំនន់ | | | | កង្វះខាតទឹក | | សត្វល្អិត | | ទឹកជំនន់ | | | | | |
| | | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ |
| បន្ទាយមានជ័យ | 246,021 | 26 | 97,251 | | | | | **26** | **97,251** | - | 10,799 | | | | | - | **10,799** | - | - |
| បាត់ដំបង | 290,056 | - | 64,828 | | | | | - | **64,828** | - | 23,885 | | | | | - | **23,885** | - | 12,952 |
| កំពង់ចាម | 87,146 | 87 | 3,755 | | | | | **87** | **3,755** | - | - | | | | | - | - | - | - |
| កំពង់ឆ្នាំង | 122,581 | 487 | 2,920 | | | | | **487** | **2,920** | - | 98 | | | | | - | **98** | - | - |
| កំពង់ស្ពឺ | 112,647 | 1,712 | 3,813 | | | | | **1,712** | **3,813** | 64 | - | | | | | **64** | - | - | - |
| កំពង់ធំ | 213,426 | - | 4,390 | | | | | - | **4,390** | - | - | | | | | - | - | - | - |
| កំពត | 136,537 | | | | | | | - | - | | | | | | | - | - | | |
| កណ្តាល | 35,280 | 245 | 1,175 | | | | | **245** | **1,175** | - | - | | | | | - | - | - | - |
| កោះកុង | 10,405 | | | | | | | - | - | | | | | | | - | - | | |
| ក្រចេះ | 32,286 | 14 | 230 | | | | | **14** | **230** | 7 | 83 | | | | | **7** | **83** | 7 | 83 |
| មណ្ឌលគិរី | 22,929 | | | | | | | - | - | | | | | | | - | - | | |
| ភ្នំពេញ | 11,153 | - | 170 | | | | | - | **170** | - | - | | | | | - | - | - | |
| ព្រះវិហារ | 83,388 | | | | | | | - | - | | | | | | | - | - | | - |
| ព្រៃវែង | 268,315 | 15 | 2,513 | | | | | **15** | **2,513** | - | - | | | | | - | - | - | - |
| ពោធិសាត់ | 108,329 | - | 24,387 | | | | | - | **24,387** | - | 2,936 | | | | | - | **2,936** | - | 200 |
| រតនគិរី | 26,018 | | | | | | | - | - | | | | | | | - | - | | |
| សៀមរាប | 186,050 | - | 830 | | | | | - | **830** | - | 830 | | | | | - | **830** | - | - |
| ព្រះសីហនុ | 16,614 | | | | | | | - | - | | | | | | | - | - | | |
| ស្ទឹងត្រែង | 28,689 | | | | | | | - | - | | | | | | | - | - | | |
| ស្វាយរៀង | 167,946 | - | 10,323 | | | | | - | **10,323** | - | 1,138 | | | | | - | **1,138** | - | 850 |
| តាកែវ | 197,234 | 10 | 13,638 | | | | | **10** | **13,638** | - | 1,252 | | | | | - | **1,252** | - | 1,252 |
| ឧត្តរមានជ័យ | 72,000 | - | 12,027 | | | | | - | **12,027** | - | - | | | | | - | - | - | - |
| កែប | 3,588 | | | | | | | - | - | | | | | | | - | - | | |
| ប៉ៃលិន | 5,001 | - | 166 | | | | | - | **166** | - | 121 | | | | | - | **121** | | 45 |
| ត្បូងឃ្មុំ | 78,318 | | | | | | | - | - | | | | | | | - | - | | |
| សរុប | **2,561,957** | **2,596** | **242,416** | - | - | - | - | **2,596** | **242,416** | **71** | **41,142** | - | - | - | - | **71** | **41,142** | **7** | **15,382** |

**បានឃើញនិងឯកភាព**

ក. ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

**ផ្ទៃដីប៉ះពាល់សរុបមាន 245,012 ហ.ត**

ភ្នំពេញ, ថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០១៥

ប្រធានការិយាល័យស្ថិតិ